# ការចាក់វ៉ាក់សាំងកូវ៉ីណាថ្មីសម្រាប់សិក្ខាកាម




បច្ចុប្បន្នការចាក់ថ្នាំវ៉ាក់សាំងការពារកូវ៉ីណាថ្មីកំពុងដំណើរការ។ជនបរទេសដែលកំពុងរស់នៅក្នុងប្រទេសជប៉ុននិងរួមទាំងសិក្ខាកាមដែលមានបំណងទទួលថ្នាំវ៉ាក់សាំងគឺអាចទទួលបានចាការក់វ៉ាក់សាំងនេះដោយឥតគិតថ្លៃ។ការចាក់ថ្នាំវ៉ាក់សាំងនេះនឹងត្រូវធ្វើឡើងចំនួន2ដង ។

## ការចាក់ថ្នាំតាមការសម្រេចចិត្តរបស់អ្នក

នៅក្រោមច្បាប់របស់ប្រទេសជប៉ុនការចាក់វ៉ាក់សាំងគឺប្រព្រឹត្តឡើងដោយការសំរេចចិត្តរបស់បុគ្គលផ្ទាល់។ប្រសិនបើខាងក្រុមហ៊ុនណែនាំឱ្យចាក់វ៉ាក់សាំងក្រុមហ៊ុនត្រូវចាំបាច់ពន្យល់ដល់បុគ្គលិករបស់ខ្លួនអោយគួរសម។ប្រសិនបើករណីការចាក់វ៉ាក់សាំងបណ្តាលឱ្យប៉ះពាល់សុខភាពធ្ងន់ធ្ងរនោះនឹងមានសំណងផ្អែកលើច្បាប់ប្រទេសជប៉ុន។

## នីតិវិធីចាក់ថ្នាំវ៉ាក់សាំងគឺដូចគ្នាទៅនឹងជនជាតិជប៉ុនដែរ។

1.ប័ណ្ណចាក់ថ្នាំវ៉ាក់សាំងនឹងត្រូវបានផ្ញើរពីសាលាក្រុងរបស់អ្នកទៅតាមអាសយដ្ឋាននៅលើប័ណ្ណស្នាក់នៅរបស់អ្នក។
2.ធ្វើការកក់ចាក់ថ្នាំវ៉ាក់សាំង
3.ទទួលការចាក់ថ្នាំនៅមជ្ឈមណ្ឌលចាក់ថ្នាំវ៉ាក់សាំង

**នីតិវិធីចាក់វ៉ាក់សាំង**

**【អ្វីដែលត្រូវយកទៅមជ្ឈមណ្ឌលចាក់ថ្នាំវ៉ាក់សាំង】**

ប័ណ្ណចាក់វ៉ាក់សាំង,ក្រដាសពិនិត្យសុខភាព(ភាសាជប៉ុន),ឯកសារបញ្ជាក់អត្តសញ្ញាណ(ប័ណ្ណស្នាក់នៅរឺកាត マイナンバーカード។

## ការបំពេញក្រដាសពិនិត្យសុខភាពជាភាសាជប៉ុន

សូមអានក្រដាសណែនាំអំពីថ្នាំវ៉ាក់សាំងនិងក្រដាសពិនិត្យសុខភាពដែលបានបកប្រែរួចដោយប្រុងប្រយ័ត្ន។បន្ទាប់ពីនោះសូមបំពេញព័ត៌មានចាំបាច់ទៅលើក្រដាសពិនិត្យសុខភាពភាសាជប៉ុនដែលមាននៅក្នុងស្រោមសំបុត្រ។

**ការណែនាំអំពីថ្នាំវ៉ាក់សាំង (ក្រុមហ៊ុនភីហ្វាយស័រ)**

**ការណែនាំអំពីថ្នាំវ៉ាក់សាំង (ក្រុមហ៊ុនម៉ូឌែរណា)**

## តោះពួកយើងសាកសុំអោយជនជាតិជប៉ុនជួយ

ចំពោះការចាក់ថ្នាំវ៉ាក់សាំង អ្នកត្រូវការចេះភាសាជប៉ុនខ្លះៗ។តោះសាកសុំជនជាតិជប៉ុនដែលនៅជុំវិញយើងអោយជួយ។

- ការបញ្ជាក់ពីការទទួលបានក្រដាសចាក់ថ្នាំវ៉ាក់សាំង
- ការពន្យល់អំពីថ្នាំវ៉ាក់សាំង ,ការបញ្ជាក់ពីចេតនាចាក់ថ្នាំវ៉ាក់សាំង
- ការកក់សម្រាប់ការទទួលចាក់ថ្នាំវ៉ាក់សាំង
- ការបំពេញក្រដាសពិនិត្យសុខភាពភាសាជប៉ុន
- ព័ត៌មានទៅកាន់កន្លែងចាក់ថ្នាំវ៉ាក់សាំង

## ចូលប្រុងប្រយ័ត្នការឆ្លងមេរោគកូវ៉ីណានៅតាមរថយន្ត !

មានករណីការឆ្លងរីករាលដាលជាច្រើននៅពេលធ្វើដំណើរតាមរថយន្តឬពេលសម្រាក។នៅថ្ងៃដែលក្តៅវាពិបាកប៉ុន្តែសូមព្យាយាមអោយមានខ្យល់ចេញចូលក្នុងរថយន្តតាមដែលអាចធ្វើទៅបាន។បច្ចុប្បន្ននេះប្រភេទមេរោគdeltaមានការឆ្លងរាលដាលខ្លាំងជាងមេរោគកូវ៉ីណាធម្មតា។សូមចៀសវាងទទួលទានអាហារនិងភេសជ្ជៈក្នុងរថយន្តនិងពាក់ម៉ាស់ក្នុងពេលធ្វើដំណើរឬពេលសំរាកហើយនិងរក្សាការសន្ទនាឱ្យសមរម្យ។

**ចំពោះឈ្មោះនិងអាស័យដ្ឋានចូរបំពេញជាភាសាជប៉ុនដូចដែលមាននៅលើស្រោមសំបុត្រ។**

ក្រដាសពិនិត្យសុខភាពជាភាសាខ្មែរ




